**EMBASSY OF JAPAN**
**IN THE KINGDOM OF CAMBODIA**

# PRESS RELEASE

No.12 PR-21/EoJ 9 March 2021

## Japan Provides US$ 852,189 for Promoting Community Health and Sanitation and Hygiene, and for Raising Awareness of Environment Issues

The Government of Japan has agreed to provide US$852,189 in total for two recipient organizations under the framework, *The Grant Assistance for Japanese NGO Projects*. The Grant Contract was signed today between H.E. Mr. MIKAMI Masahiro, Ambassador Extraordinary and Plenipotentiary of Japan to the Kingdom of Cambodia, and the representatives of the two recipients respectively, to carry out the following projects:

1. 'Integrated Health, Nutrition and WASH Project in Preah Vihear (Year 2)' (US$760,341)
Recipient: World Vision Japan (WVJ)

In this project, WVJ will continue to conduct training and awareness raising sessions about health, nutrition, and WASH (Water, Sanitation and Hygiene) to health and rural development officers as well as communities in Preah Vihear province aiming to improve feeding practices and usage of safe water. The organization will also support to formulate water management committees and sanitation action groups in order to maintain safe water quality and better hygienic environment in the targeted area.

2. 'Realization of sustainable life environment around Cambodian citizens through promoting and raising awareness of environment issues (Year 1)' (US$91,848)
Recipient: Non-profit organization Nature Center Risen

In this project, Nature Center Risen will promote and increase fundamental environmental awareness across Cambodia by creating educational materials to improve environmental literacy of the citizens, providing tools for research and observation of the environment and implementing training for environment education in collaboration with pagodas and health centers. Through this project, over 300 people in Cambodia are supposed to play a core role in promoting and raising awareness of environmental issues to the citizens. This will help improve

the life environment in the whole Cambodia.

*The Grant Assistance for Japanese NGO Projects* started in Cambodia in 2002 to support activities by Japanese NGOs to help Cambodia's reconstruction and development efforts at the grassroots level. Since 2002, the Government of Japan has provided over US$45 million for 138 projects, mainly in the field of primary education, health, agriculture and mine clearance in Cambodia.

With an effort to contain the current “COVID-19 Community Outbreak”, known as “February 20 Community Event”, both sides signed the Grant Contract separately.

---

*Embassy of Japan in the Kingdom of Cambodia*
*Tel: 023-217-161, fax: 023-214-330*
*Email: eco.jpn@pp.mofa.go.jp*
*Website: http://www.kh.emb-japan.go.jp*

**ស្ថានទូតជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**សេចក្តីប្រកាសព័ត៌មាន**

លេខ. 12 PR-21/EoJ ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

# ជប៉ុនផ្តល់ ៨៥២,១៨៩ ដុល្លារអាមេរិក សម្រាប់ការលើកកម្ពស់សុខភាព និងអនាម័យសហគមន៍ និងសម្រាប់ការបង្កើនការយល់ដឹងអំពីបញ្ហាបរិស្ថាន

រដ្ឋាភិបាលជប៉ុន បានឯកភាពផ្តល់ថវិកាសរុបចំនួន ៨៥២,១៨៩ ដុល្លារអាមេរិក ដល់អង្គភាពទទួលជំនួយចំនួនពីរ ក្រោមគ្រោងការណ៍ជំនួយឥតសំណងសម្រាប់គម្រោងរបស់អង្គការក្រៅរដ្ឋាភិបាលជប៉ុន។ កិច្ចសន្យាផ្តល់ជំនួយ ត្រូវបានចុះហត្ថលេខានៅថ្ងៃនេះ ដោយ **ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ** ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាពរបស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា និង អ្នកតំណាងអង្គភាពទទួលជំនួយចំនួនពីរ សម្រាប់អនុវត្តគម្រោងដូចតទៅ៖

១. "គម្រោងការរួមបញ្ចូលគ្នា សុខភាព អាហារូបត្ថម្ភ ទឹកស្អាត និងអនាម័យ ក្នុងខេត្តព្រះវិហារ (ឆ្នាំទី២) (ថវិកាជំនួយ ៧៦០,៣៤១ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ អង្គការ World Vision Japan (WVJ)

នៅក្នុងគម្រោងនេះ អង្គការ WVJ នឹងបន្តដំណើរការវគ្គបណ្តុះបណ្តាល និងលើកកម្ពស់ការយល់ដឹងអំពីសុខភាព អាហារូបត្ថម្ភ និង WASH (ទឹកស្អាត និងអនាម័យ) ដល់មន្ត្រីសុខាភិបាល មន្ត្រីអភិវឌ្ឍន៍ជនបទ និងសហគមន៍នានា នៅក្នុងខេត្តព្រះវិហារ ក្នុងគោលបំណងកែលម្អវិធីសាស្ត្រក្នុងការរៀបចំចំណីអាហារ និងការប្រើប្រាស់ទឹកស្អាត។ អង្គការនេះក៏នឹងគាំទ្រក្នុងការបង្កើតគណៈកម្មាធិការគ្រប់គ្រងទឹកស្អាត និងក្រុមជនបង្គោលអនាម័យ ដើម្បីរក្សាគុណភាពទឹកស្អាត និងបរិស្ថានអនាម័យដែលល្អប្រសើរជាងមុន នៅក្នុងតំបន់គោលដៅ។

២. "ការសម្រេចឱ្យបាននូវបរិស្ថានរស់នៅប្រកបដោយចីរភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់ និងអប់រំការយល់ដឹងអំពីបញ្ហាបរិស្ថាន (ឆ្នាំទី១) (ថវិកាចំនួន ៩១,៨៤៨ ដុល្លារអាមេរិក)

អង្គភាពទទួលជំនួយ៖ អង្គការ Nature Center Risen

នៅក្នុងគម្រោងនេះ អង្គការ Nature Center Risen នឹងលើកកម្ពស់ និងបង្កើនការយល់ដឹងជាមូលដ្ឋានអំពីបរិស្ថាន នៅទូទាំងប្រទេសកម្ពុជា តាមរយៈការរៀបចំឯកសារអប់រំថ្មីៗ ដើម្បីកែលម្អចំណេះដឹងផ្នែកបរិស្ថានរបស់ប្រជាពលរដ្ឋ ការផ្តល់នូវឧបករណ៍ផ្សេងៗសម្រាប់ការស្រាវជ្រាវ និងការសង្កេតផ្នែកបរិស្ថាន និងការអនុវត្តការបណ្តុះបណ្តាលស្តីពីការអប់រំបរិស្ថាន ដោយសហការជាមួយវត្តអារាម និងមណ្ឌលសុខភាព។ តាមរយៈគម្រោងនេះ ប្រជាជនកម្ពុជាជាង ៣០០ នាក់ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងអំពីបញ្ហាបរិស្ថានដល់ប្រជាពលរដ្ឋ។ គម្រោងនេះ នឹងជួយធ្វើឱ្យប្រសើរឡើងនូវបរិស្ថានជីវិតនៅក្នុងប្រទេសកម្ពុជាទាំងមូល។

កម្មវិធីជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមនៅប្រទេសកម្ពុជា តាំងពីឆ្នាំ២០០២ ដើម្បីគាំទ្រដល់សកម្មភាពអង្គការក្រៅរដ្ឋាភិបាលជប៉ុន ក្នុងកិច្ចខិតខំប្រឹងប្រែង ដើម្បីជួយដល់ការអភិវឌ្ឍ និងស្តាបនាប្រទេសកម្ពុជាឡើងវិញនៅតាមកម្រិតមូលដ្ឋាន។ ចាប់តាំងពីឆ្នាំ២០០២មក រដ្ឋាភិបាលជប៉ុន បានផ្តល់ថវិកាជាង ៤៥លាន ដុល្លារអាមេរិក ដល់គម្រោងចំនួន ១៣៨ ដែលផ្តោតសំខាន់ទៅលើវិស័យអប់រំនៅកម្រិតមូលដ្ឋាន វិស័យសុខាភិបាល វិស័យកសិកម្ម និងសកម្មភាពបោសសម្អាតមីនក្នុងប្រទេសកម្ពុជា។

ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ ដាច់ដោយឡែកពីគ្នា ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ ការរីករាលដាលចូលសហគមន៍នៃវីរុសកូវីត១៩ ដែលហៅថា "ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ"។

---

ស្ថានទូតជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទ៖ ០២៣-២១៧-១៦១ ទូរសារ៖ ០២៣-២១៤-៣៣០
អ៊ីម៉ែល៖ eco.jpn@.pp.mofa.go.jp
គេហទំព័រ៖ http://www.kh.emb-japan.go.jp

ថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១

នៅថ្ងៃទី៩ ខែមីនា កិច្ចសន្យាផ្តល់ជំនួយឥតសំណងសម្រាប់គម្រោងអង្គការក្រៅរដ្ឋាភិបាលជប៉ុនត្រូវបានចុះហត្ថលេខា។ ភាគីទាំងពីរបានចុះហត្ថលេខាលើកិច្ចសន្យាផ្តល់ជំនួយ និងឯកសារពាក់ព័ន្ធនានា ដាច់ដោយឡែកពីគ្នា ដើម្បីចូលរួមក្នុងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ការរីករាលដាលចូលសហគមន៍នៃវីរុសកូវីត១៩ ក្នុង "ព្រឹត្តិការណ៍សហគមន៍ ២០កុម្ភៈ"។ ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ស្ថានភាពនឹងមានភាពប្រសើរឡើងក្នុងពេលឆាប់ៗនេះ។

រដ្ឋាភិបាលជប៉ុន បានចាប់ផ្តើមហិរញ្ញប្បទានឥតសំណង សម្រាប់អង្គការក្រៅរដ្ឋាភិបាលជប៉ុនចាប់តាំងពីឆ្នាំ២០០២ ដើម្បីជួយដល់គម្រោងអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម របស់អង្គការក្រៅ រដ្ឋាភិបាលជប៉ុនក្នុងប្រទេស ឬតំបន់កំពុងអភិវឌ្ឍន៍។ រហូតមកដល់ពេលនេះ ស្ថានទូតជប៉ុនបាន ផ្តល់ជំនួយជាង ១៣០គម្រោងនៅកម្ពុជាតាមរយៈកម្មវិធីនេះ។ គម្រោងនីមួយៗបានចូលរួមចំណែកក្នុងការលើកកម្ពស់គុណភាពជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា។

នៅថ្ងៃនេះ ខ្ញុំបានចុះហត្ថលេខាលើគម្រោងដូចខាងក្រោម៖

**អង្គភាពទទួលជំនួយ៖ អង្គការ** World Vision Japan (WVJ)
**ឈ្មោះគម្រោង៖ គម្រោងការរួមបញ្ចូលគ្នា សុខភាព អាហារូបត្ថម្ភ ទឹកស្អាតនិងអនាម័យ ក្នុងខេត្តព្រះវិហារ (ឆ្នាំទី២)**

**អង្គភាពទទួលជំនួយ៖ អង្គការ** Nature Center Risen
**ឈ្មោះគម្រោង៖ ការសម្រេចឱ្យបាននូវបរិស្ថានរស់នៅប្រកបដោយចីរភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការលើកកម្ពស់ និងអប់រំការយល់ដឹងអំពីបញ្ហាបរិស្ថាន (ឆ្នាំទី១)**

ខ្ញុំសូមជម្រាបជូនអំពីគម្រោងនីមួយៗដែលបានចុះហត្ថលេខាដូចតទៅ៖

សម្រាប់គម្រោងទីមួយ រដ្ឋាភិបាលជប៉ុនផ្តល់ថវិកាចំនួន ៧៦០,៣៩១ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការ World Vision Japan (WVJ)។ អង្គការនេះ បាននិងកំពុងធ្វើការលើផ្នែកសុខភាព អនាម័យ ការអប់រំ និងសកម្មភាពបង្កើនប្រាក់ចំណូលនៅតាមបណ្តាខេត្តនានាក្នុងប្រទេសកម្ពុជាតាមរយៈការអភិវឌ្ឍសហគមន៍។ នៅក្នុងឆ្នាំទី២ នៃគម្រោងដែលមានរយៈពេល៣ឆ្នាំនេះ អង្គការ WVJ នឹងបន្តដំណើរការវគ្គបណ្តុះបណ្តាលសុខភាពមាតា សម្រាប់បុគ្គលិកសុខាភិបាល និងក្រុមគាំទ្រសុខភាពភូមិ និងវគ្គបណ្តុះបណ្តាលលើកកម្ពស់អាហារូបត្ថម្ភ សម្រាប់ក្រុមគាំទ្រម្តាយ ព្រមទាំងបន្តកសាងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតផងដែរ។ លើសពីនេះ គម្រោងនេះនឹងចាប់ផ្តើមបង្កើត "ហឹបសុខភាពអាហារូបត្ថម្ភសហគមន៍" នៅក្នុងតំបន់គោលដៅ និងអនុវត្តយុទ្ធនាការសំអាតសហគមន៍ ចាប់ពីឆ្នាំនេះតទៅ។ ខ្ញុំសូមសម្តែងការគោរព ចំពោះការចូលរួមចំណែក របស់អង្គការ World Vision Japan នៅក្នុងការ

លើកកម្ពស់អាហារូបត្ថម្ភ និងអនាម័យអស់រយៈពេលជាច្រើនឆ្នាំ។ ខ្ញុំក៏សង្ឃឹមថាស្ថានភាពអាហារូបត្ថម្ភ និងសុខភាពរបស់កុមារ នឹងមានភាពប្រសើរឡើង ហើយប្រជាជននៅក្នុងសហគមន៍នឹងអាចប្រើប្រាស់ទឹកដែលមានសុវត្ថិភាព តាមរយៈគម្រោងនេះ។

សម្រាប់គម្រោងទី២ រដ្ឋាភិបាលជប៉ុននឹងផ្តល់ថវិកាចំនួន ៩១,៨៩៨ ដុល្លារអាមេរិក សម្រាប់គម្រោងដែលអនុវត្តដោយអង្គការ Nature Center Risen។ អង្គការនេះបាន និងកំពុងខិតខំប្រឹងប្រែងលើកកម្ពស់ស្មារតីបរិស្ថានរបស់យុវជន តាមរយៈការអប់រំនៅតាមសាលារៀន នៅក្នុងប្រទេសកម្ពុជា តាំងពីឆ្នាំ២០១៣។ នៅក្នុងគម្រោងនេះ ពួកគេនឹងអនុវត្តសកម្មភាពលើកកម្ពស់ការយល់ដឹងអំពីបរិស្ថានដល់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការរៀបចំឯកសារអប់រំថ្មីៗ ដើម្បីកែលម្អចំណេះដឹងផ្នែកបរិស្ថានរបស់ប្រជាពលរដ្ឋកម្ពុជាឲ្យមានប្រសិទ្ធិភាព ការផ្តល់នូវឧបករណ៍ផ្សេងៗសម្រាប់ការសិក្សាស្រាវជ្រាវ និងការសង្កេតផ្នែកបរិស្ថាន និងការអនុវត្តការបណ្តុះបណ្តាលស្តីពីការអប់រំបរិស្ថានដោយគ្រូបង្វឹកជនជាតិជប៉ុន។ ខ្ញុំសូមសម្តែងការគោរពចំពោះការលះបង់ និងការចូលរួមចំណែករបស់អង្គការ Nature Center Risen នៅក្នុងសកម្មភាពលើកកម្ពស់ការយល់ដឹងនានា ដើម្បីបង្កើនស្មារតីបរិស្ថាននៅក្នុងប្រទេសកម្ពុជា។ ខ្ញុំក៏សង្ឃឹមថាតាមរយៈគម្រោងនេះ ជនជាតិខ្មែរគ្រប់វ័យទាំងអស់ នឹងយល់ដឹងអំពីសារៈសំខាន់នៃការថែរក្សាបរិស្ថាន ដែលនឹងធ្វើឲ្យប្រសើរឡើងនូវបរិស្ថានជីវិត នៅក្នុងប្រទេសកម្ពុជាទាំងមូល។

ខ្ញុំសង្កេតឃើញថានាពេលថ្មីៗនេះ ប្រទេសកម្ពុជាបាននិងកំពុងអភិវឌ្ឍយ៉ាងឆាប់រហ័ស។ ប៉ុន្តែនៅតែមានបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ ដូចជាការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម ដែលរួមមានវិស័យសុខាភិបាល និងបរិស្ថានអប់រំ ដើម្បីកែលម្អនូវគុណភាពជីវភាពរស់នៅរបស់ប្រជាជន។ ទោះបីជាការរីករាលដាលនៃវីរុសកូវីត១៩ កំពុងក្លាយជាបញ្ហាដ៏ធ្ងន់ធ្ងរនៅទូទាំងពិភពលោកយ៉ាងណាក៏ដោយ ប្រទេសជប៉ុននឹងបន្តសហការជាមួយអង្គការក្រៅ រដ្ឋាភិបាលដើម្បីដោះស្រាយបញ្ហាប្រឈមនានា។

ខ្ញុំសូមជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សូមមានសុខភាពល្អ សុភមង្គល និងសូមឲ្យមិត្តភាពជប៉ុន-កម្ពុជាកាន់តែរីកចម្រើន។

ឯកឧត្តម មិកាមិ ម៉ាសាហ៊ីរ៉ូ<br>
ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព<br>
របស់ប្រទេសជប៉ុនប្រចាំព្រះរាជាណាចក្រកម្ពុជា